# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំបន្តចរន្តអគ្គិសនី

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ........................................ ជាអក្សរឡាតាំង........................................
ភេទ.......... ជនជាតិ................ សញ្ជាតិ................ មុខរបរ.......................................... អាសយដ្ឋានបច្ចុប្បន្ន
ផ្ទះលេខ ............. ផ្លូវ ......... ភូមិ........................ ឃុំ/សង្កាត់ ............................. ស្រុក/ខណ្ឌ .....................
ខេត្ត/រាជធានី............ លេខទូរស័ព្ទ.......................... ☐WhatsApp ☐Telegram E-mail...........................។

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
## អគ្គនាយកអគ្គិសនីកម្ពុជា

**កម្មវត្ថុ ៖** សំណើសុំ ☐បង្កើនកម្លាំង ☐បន្ថយកម្លាំង ☐បន្តចរន្តថ្មី កម្លាំង..................................................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា នៅទីតាំងប្រើប្រាស់ចរន្តអគ្គិសនីឈ្មោះ..............................................................................................
មានអាសយដ្ឋាន.............................. ផ្លូវ.................... ភូមិ...................... ឃុំ/សង្កាត់..........................
ស្រុក/ខណ្ឌ.......................... ខេត្ត/រាជធានី.................... កន្លងមក ☐មិនធ្លាប់ ☐ធ្លាប់ ប្រើប្រាស់ចរន្តអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅបន្ទប់ភ្លើងលេខ.................។ បច្ចុប្បន្នទីតាំងនេះត្រូវការចរន្តអគ្គិសនី ដើម្បីប្រើប្រាស់ជាប្រភេទ ☐ លំនៅដ្ឋាន ☐ រដ្ឋបាលសាធារណៈ ☐ ពាណិជ្ជកម្ម ☐ ឧស្សាហកម្ម ☐ កសិកម្ម ☐ បុរី ☐ សំណង់ផ្ទះល្វែង។

**ជូនភ្ជាប់មកជាមួយនូវ៖** ឯកសារពាក់ព័ន្ធចាំបាច់តាមសេចក្តីណែនាំរបស់អគ្គិសនីកម្ពុជា លេខ ០៧៨៥ សណន.អក.អច ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០។

ខ្ញុំសូមបញ្ជាក់ថា រាល់ព័ត៌មានដែលបានបំពេញ និងឯកសារភ្ជាប់មកជាមួយពាក្យស្នើសុំបន្តចរន្តអគ្គិសនីនេះ គឺពិត និងត្រឹមត្រូវ ករណីក្លែងបន្លំ ខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ថ្ងៃ.........................ខែ..................ឆ្នាំ..............ព.ស២៥.......
រាជធានីភ្នំពេញ, ថ្ងៃទី ......... ខែ ........... ឆ្នាំ២០.......
**ស្នាមមេដៃ ឬហត្ថលេខា និងត្រា អ្នកស្នើសុំ**

**កន្លែងទទួលពាក្យ ៖** នៅការិយាល័យទំនាក់ទំនងព័ត៌មាន និងសរុប នាយកដ្ឋានអាជីវកម្មចែកចាយ នៃអគ្គិសនីកម្ពុជា
ទូរស័ព្ទលេខ 017/016-598-877

# បញ្ជីរាយឈ្មោះឧបករណ៍ប្រើប្រាស់ថាមពលអគ្គិសនី នៅលើទីតាំងស្នើសុំបន្តចរន្តអគ្គិសនី

**ប្រភេទប្រើប្រាស់៖** ☐លំនៅដ្ឋាន ☐រដ្ឋបាលសាធារណៈ ☐ពាណិជ្ជកម្ម ☐ឧស្សាហកម្ម ☐កសិកម្ម ☐បុរី ☐សំណង់ផ្ទះល្វែង

| ល.រ | ឧបករណ៍ប្រើប្រាស់ | ឯកតា | ចំនួន | អានុភាព ១ឯកតា | អានុភាព សរុប | ចំនួនហ្វា | តង់ស្យុង | Cosø | រយៈពេលប្រើក្នុង ២៤ម៉ | | កាលបរិច្ឆេទ ផ្ដើមដំណើរការ ឧបករណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ថ្ងៃ | យប់ | |
| A | ផ្នែកបំភ្លឺ | | | | | | | | | | |
| 1 | អំពូលម៉ែត្រទំហំ វ៉ាត់ | គ្រ | | | | | | | | | |
| 2 | អំពូលម៉ែត្រទំហំ វ៉ាត់ | គ្រ | | | | | | | | | |
| 3 | អំពូលម៉ែត្រទំហំ វ៉ាត់ | គ្រ | | | | | | | | | |
| 4 | អំពូលម៉ែត្រទំហំ វ៉ាត់ | គ្រ | | | | | | | | | |
| 5 | | គ្រ | | | | | | | | | |
| 6 | | គ្រ | | | | | | | | | |
| | សរុប | | | | | | | | | | |
| B | ផ្នែកគ្រឿងម៉ាស៊ីន | | | | | | | | | | |
| 1 | | គ្រ | | | | | | | | | |
| 2 | | គ្រ | | | | | | | | | |
| 3 | | គ្រ | | | | | | | | | |
| 4 | | គ្រ | | | | | | | | | |
| 5 | | គ្រ | | | | | | | | | |
| 6 | | គ្រ | | | | | | | | | |
| 7 | | គ្រ | | | | | | | | | |
| 8 | | គ្រ | | | | | | | | | |
| 9 | | គ្រ | | | | | | | | | |
| 10 | | គ្រ | | | | | | | | | |
| 11 | | គ្រ | | | | | | | | | |
| 12 | | គ្រ | | | | | | | | | |
| 13 | | គ្រ | | | | | | | | | |
| | សរុប | | | | | | | | | | |

បញ្ជាក់៖ ករណីមានការផ្លាស់ប្តូរ ឬបង្កើនឧបករណ៍ប្រើប្រាស់ និងមានការកែប្រែកាលបរិច្ឆេទដំណើរការឧបករណ៍ នោះអតិថិជនចាំបាច់ជូនដំណឹងមកអគ្គិសនីកម្ពុជា ដើម្បីត្រួតពិនិត្យ។

| មតិប្រធានការិយាល័យបច្ចេកទេសចែកចាយ | មតិផ្នែកគំពោងការ | បញ្ជាក់ថា ត្រឹមត្រូវពិតប្រាកដ<br>អ្នកស្នើសុំ |
|---|---|---|
| | | |

# កម្មវិធីបន្តចរន្តជូនអតិថិជនធុនមធ្យម និងធុនធំ




**សំគាល់**

- ការិ.ទពស : ការិយាល័យទំនាក់ទំនងព័ត៌មាន និងសរុប
- ការិ.បចច : ការិយាល័យបច្ចេកទេសចែកចាយ
- ការិ.ផផស : ការិយាល័យផែនការផ្គត់ផ្គង់សម្ភារ
- អ. បណ្តាញ : អង្គភាពបណ្តាញ
- ការិ.Billing : ការិយាល័យគ្រប់គ្រងទិន្នន័យ និងបោះពុម្ពវិក្កយបត្រ
- DCC : មជ្ឈមណ្ឌលបញ្ជា
- ន.IT : នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- អ.ជ : អតិថិជន
- X : រយៈពេលក្រៅពីការទទួលខុសត្រូវរបស់ EDC

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២០
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកអគ្គិសនីកម្ពុជា

ELECTRICITE DU CAMBODGE

កែវ រតនៈ

៣

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ: ៣១០៨ អ៨៣.អក

## សេចក្ដីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយសសូមជំរាបជូនដល់សាធារណៈជន និងអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : កន្លងមកនេះ អគ្គិសនីកម្ពុជាបានស្រាវជ្រាវឃើញជាបន្តបន្ទាប់ នូវបទល្មើសលួចថាមពលអគ្គិសនីដែលរួមមាន ផ្តាច់សំណប៉ាំបេដើម្បីកែច្នៃប្រព័ន្ធនាឡិកាស្ទង់ បង្វិលលេខអំណាននាឡិកាស្ទង់ថយក្រោយ ប្រើប្រាស់សំណប៉ាំបេដង្កាប់ក្លែងក្លាយ ប្តូរត្រឡប់ខ្សែចេញចូលនាឡិកាស្ទង់ លួចប្រើប្រាស់អគ្គិសនីក្រៅនាឡិកាស្ទង់ឬប្រើប្រាស់អគ្គិសនីពីប្រភពផ្សេងទៀត ដែលជនខិលខូចលួចបន្តឱ្យ និងមានរូបភាពល្មើសផ្សេងៗទៀត ។ អគ្គិសនីកម្ពុជា បានប្រើវិធានការទៅតាមច្បាប់ ក្នុងការរំលឹកពិន័យជាទំងន់ដល់អ្នកបានប្រព្រឹត្តល្មើស ព្រមទាំងអ្នករួមគំនិត និងកសាងឯកសារបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច និង ស្ថាប័នតុលាការ ដើម្បីវិនិច្ឆ័យទោសដល់ជនល្មើស និងជនពាក់ព័ន្ធទៅតាមទំហំនៃបទល្មើសរបស់ខ្លួន ។ បច្ចុប្បន្នអគ្គិសនីកម្ពុជាកំពុងបន្តចាត់វិធានការបន្ថែមក្នុងការស្រាវជ្រាវរកបទល្មើសលួចថាមពលអគ្គិសនី ដែលអតិថិជនមួយចំនួនតូចបានកំពុងបន្តប្រព្រឹត្ត ឬ ឃុបឃិតជាមួយជនខិលខូច ។

អគ្គិសនីកម្ពុជាសំណូមពរឱ្យអតិថិជនមានការប្រុងប្រយ័ត្ននូវការបោកបញ្ឆោតពីជនពុំស្គាល់អត្តសញ្ញាណពិតប្រាកដ ដែលទៅទំនាក់ទំនងជួសជុលកែច្នៃប្រព័ន្ធនាឡិកាស្ទង់ឬខ្សែបន្តអគ្គិសនីរបស់ខ្លួន ។ ករណីមានការសង្ស័យលើបទល្មើសលួចថាមពលអគ្គិសនី ឬលួចបំផ្លាញបរិក្ខារប្រព័ន្ធបណ្តាញរបស់អគ្គិសនីកម្ពុជា សូមអតិថិជន ឬ សាធារណៈជនមេត្តាប្តឹងទៅអាជ្ញាធរមូលដ្ឋាន ឬ សូមមេត្តាទាក់ទងនឹងអគ្គិសនីកម្ពុជាទូរស័ព្ទលេខ : ០២៣ ៤២៧ ៦២៦ ឬ ០១៦ ៨១២ ៦៩៤ ឬ ០១២ ២៦៦ ៦១៥ ដើម្បីចាត់វិធានការបង្ក្រាបបានទាន់ពេលវេលា ។

ក្នុងករណីមានការផ្ទេរឈ្មោះអ្នកជាវ ប្តូរប្រភេទប្រើប្រាស់ ជួលទីតាំង និងផ្លាស់ប្តូរម្ចាស់ទីតាំង អ្នកប្រើប្រាស់ថ្មីចាំបាច់ត្រូវទៅទំនាក់ទំនងនៅសាខាអគ្គិសនីកម្ពុជា ដើម្បីស្នើសុំឱ្យត្រួតពិនិត្យបំណុល និង ស្ថានភាពប្រព័ន្ធនាឡិកាស្ទង់ជូនជាមុន ។ បើពុំនោះទេ អាចនឹងកើតមានបាតុភាពបំណុលដែលនៅសេសសល់ត្រូវធ្វើការទូទាត់ ឬ បាតុភាពការប្រើប្រាស់អគ្គិសនីកន្លងមក ដែលអ្នកប្រើប្រាស់ថ្មីត្រូវទទួលរងបន្ទុកជាបន្តទាំងស្រុង ។

អគ្គិសនីកម្ពុជា សង្ឃឹមនិងជឿជាក់ថា សាធារណៈជន និង អតិថិជនអគ្គិសនីកម្ពុជា នឹងចូលរួមជាមួយអគ្គិសនីកម្ពុជា ដើម្បីទប់ស្កាត់ឱ្យបាននូវអំពើចោរកម្មទាំងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០០៨

អគ្គនាយក អគ្គិសនីកម្ពុជា

ELECTRICITE DU CAMBODGE

កែវ រតនៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ: ៩៥១ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦

# សេចក្តីណែនាំ

ឆ្លងតាមបទពិសោធន៍កន្លងមក អគ្គិសនីកម្ពុជា បានខិតខំរៀបចំបំពេញបែបបទ និងឯកសារបន្តចរន្តជូនអតិថិជនអោយបានទាន់ពេលកំណត់ ប៉ុន្តែទន្ទឹមនឹងនេះដែរ អគ្គិសនីកម្ពុជា បានសង្កេតឃើញថា៖

អតិថិជនរបស់អគ្គិសនីកម្ពុជាមួយចំនួន ដែលបានសុំបន្តចរន្តរួចហើយ បានស្នើសុំពន្យារពេលបន្តចរន្តចូលទីតាំងរបស់ខ្លួន បើទោះបីអគ្គិសនីកម្ពុជា បានខិតខំរៀបចំតម្លើងសម្ភារបរិក្ខាអគ្គិសនីរួចស្រេចដល់មុខទីតាំង ឬដល់ចំណុចផ្គត់ផ្គង់ចរន្តរបស់អតិថិជនហើយក្តី ដោយលើកឡើងថា ទីតាំងរបស់ខ្លួនពុំទាន់បានសាងសង់ហើយ ឬសាងសង់ហើយពុំទាន់បានបំពាក់សម្ភាររួច ឬទីតាំងអតិថិជនមួយចំនួនទៀតមានតែដីឡូតិ៍ទទេ ពុំមានការស្ថាបនាអ្វីនោះឡើយ ។ ការស្នើសុំពន្យាពេលបន្តចរន្តពាក់ព័ន្ធនឹងមូលហេតុខាងលើនេះ បានបង្កការលំបាក និងប៉ះពាល់ដល់ផែនការសកម្មភាពលើការងារបន្តចរន្ត ការងាររក្សាទុកសម្ភារបរិក្ខាអគ្គិសនី ដែលបានបើកចេញពីឃ្លាំងសម្ភារ រួមទាំងការងារធានាសុវត្ថិភាពប្លុំបេសំណការពារលើប្រព័ន្ធនាឡិកាស្ទង់ CT , VT ព្រមទាំងបរិក្ខារណាបមួយចំនួនទៀត ។

ដូច្នេះ ដើម្បីសម្រួលដោះស្រាយបាតុភាពអសកម្មខាងលើនេះ អគ្គិសនីកម្ពុជា សូមធ្វើការណែនាំដល់ជំនាញពាក់ព័ន្ធដូចខាងក្រោម៖

១. រាល់សំណើសុំពន្យាពេលបន្តចរន្តចូលទីតាំងរបស់អតិថិជនគ្រប់ប្រភេទ (លើកលែងតែអតិថិជនស្ថាប័នរដ្ឋ ) អគ្គិសនីកម្ពុជាអនុគ្រោះពន្យាពេលបន្តចរន្តជូនយ៉ាងយូរត្រឹម ០៦ខែ ( ប្រាំមួយខែ ) ដោយគិតចាប់ពី ថ្ងៃបង់លុយថ្លៃសម្ភារ ពលកម្ម និងប្រាក់កក់ ។

២. ផុតកំណត់រយៈពេល ០៦ខែ (ប្រាំមួយខែ ) ដូចមានចែងក្នុងចំនុចទីមួយ អគ្គិសនីកម្ពុជាចាត់ទុកថាអតិថិជនបោះបង់ចោលការស្នើសុំបន្តចរន្តចូលទីតាំងរបស់ខ្លួន ដោយអគ្គិសនីកម្ពុជា នឹងលុបឈ្មោះអតិថិជនចេញពីបញ្ជី រួចបង្វិលតែប្រាក់កក់ដែលបានបង់រួច ជូនអតិថិជនវិញតែប៉ុណ្ណោះ ។

សូមលោកប្រធានសាខាអគ្គិសនីកម្ពុជា អង្គភាពអគ្គិសនីកម្ពុជាខេត្ត-ក្រុង និងការិយាល័យពាក់ព័ន្ធ ទាំងអស់ត្រូវមានកាតព្វកិច្ចពន្យល់ជម្រាបជូនអតិថិជនឲ្យបានយល់ និងចុះហត្ថលេខា ឬផ្តិតមេដៃទទួលស្គាល់ លើសេចក្តីណែនាំនេះ តាំងពីអតិថិជនដាក់ពាក្យស្នើសុំបន្តចរន្តដំបូង និងត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

ចម្លងជូន:

- លោកអគ្គនាយករងអគ្គិសនីកម្ពុជា
- នាយក និងនាយករងពាក់ព័ន្ធ
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ៩៥២ អគក.សក.ឈ៥

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦

# សេចក្ដីណែនាំ

យោងតាមប្រការ៤ នៃសេចក្ដីសម្រេច របស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ ៤៦១សរ-១៥ អអក ចុះថ្ងៃទី ១៨ ខែ ១១ ឆ្នាំ២០១៥ « *ស្ដីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្ដល់សេវាអគ្គិសនីត្រូវអនុវត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា* » បានអនុញ្ញាតឲ្យ អតិថិជន តម្កល់ទុកខ្សែបណ្ដាញ សម្ភារ ឧបករណ៍ ត្រង់ស្វូរ ជាការធានាផ្នែកណាមួយ ឬទាំងអស់នៃប្រាក់កក់ អាស្រ័យទៅតាមការឯកភាពរបស់ភាគីអគ្គិសនីកម្ពុជា និងភាគីអតិថិជន ។

ដើម្បីជួយសម្រាលបន្ទុកអតិថិជន ដែលបានចេញថ្លៃវិនិយោគ លើខ្សែបណ្ដាញ សម្ភារ ឧបករណ៍ ត្រង់ស្វូ ក្នុងបំណងបន្តចរន្តពីអគ្គិសនីកម្ពុជានោះ អគ្គិសនីកម្ពុជា សូមធ្វើការណែនាំដល់ជំនាញពាក់ព័ន្ធដូចខាងក្រោម:

១. អគ្គិសនីកម្ពុជា អនុគ្រោះជូនអតិថិជន ដែលបានចេញថ្លៃវិនិយោគលើខ្សែបណ្ដាញ សម្ភារ ឧបករណ៍ ត្រង់ស្វូ ។ល។ បានរួចប្រាក់កក់ថ្លៃធានាការប្រើប្រាស់ថាមពលអគ្គិសនីជាមធ្យមចំនួន ០១ខែ(មួយខែ) ក្នុងករណីអតិថិជនធានាតម្កល់ទុកខ្សែបណ្ដាញ សម្ភារ ឧបករណ៍ ត្រង់ស្វូ ជំនួសប្រាក់កក់ ដែលត្រូវកំណត់អោយបង់ ។

២. តម្លៃវិនិយោគលើខ្សែបណ្ដាញ សម្ភារ ឧបករណ៍ ត្រង់ស្វូ របស់អតិថិជន ដែលស្នើសុំតម្កល់សម្ភារជំនួសប្រាក់កក់ ត្រូវមានទំហំមិនតូចជាងប្រាក់កក់ធានាថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ជាមធ្យមចំនួន ០១ខែ (មួយខែ) ដែលបានកំណត់ដោយអាជ្ញាធរអគ្គិសនីឡើយ ។

៣. ការឯកភាពលើចំនុចទីមួយ ខាងលើនេះ ត្រូវមានចែងក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី ដូចដែលបានកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

សូមលោកប្រធានសាខាអគ្គិសនីកម្ពុជា អង្គភាពអគ្គិសនីកម្ពុជាខេត្ត-ក្រុង និងការិយាល័យពាក់ព័ន្ធ ទាំងអស់ ត្រូវមានភាតព្វកិច្ចពន្យល់ ផ្សព្វផ្សាយឲ្យបានទូលាយ ជម្រាបជូនអតិថិជនឲ្យបានយល់ លើសេចក្ដីណែនាំនេះ តាំងពីអតិថិជនដាក់ពាក្យស្នើសុំបន្តចរន្តដំបូង និងត្រូវអនុវត្តតាមសេចក្ដីណែនាំនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា

ELECTRICITE DU CAMBODGE

កែវ_រតនៈ

ចម្លងជូន:
- លោកអគ្គនាយករងអគ្គិសនីកម្ពុជា
- នាយក និងនាយករងពាក់ព័ន្ធ
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា
លេខ: ៩៩៩ ១៧៦ អក.សច

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៦

# សេចក្តីណែនាំ

យោងតាមប្រការ១ ចំណុចទី២ នៃសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ ៤៦១ សរ.១៥ អអក ចុះថ្ងៃទី១៨ ខែ១១ ឆ្នាំ២០១៥ « ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្តប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជនដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្តក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា » បានអនុញ្ញាតិឲ្យអតិថិជនធុនមធ្យម និងធុនធំ អាចតភ្ជាប់ចរន្តពីចំណុចរបស់អ្នកផ្តល់សេវាអគ្គិសនីមកប្រព័ន្ធប្រើប្រាស់របស់អ្នកប្រើប្រាស់តាមពីរជម្រើស ៖

១.អតិថិជនបង់ថ្លៃការតភ្ជាប់ខ្សែបណ្តាញ ត្រង់ស្វូ ប្រព័ន្ធន.ស និងបរិក្ខាររួមផ្សំ រួមទាំងពលកម្មទាំងអស់មកអគ្គិសនីកម្ពុជាដើម្បីឲ្យអគ្គិសនីកម្ពុជារៀបចំជូន ។

២.អតិថិជនទទួលបន្ទុកផ្គត់ផ្គង់សម្ភារអគ្គិសនីខ្លួនឯងបាន ដោយត្រូវគោរពតាមលក្ខណៈបច្ចេកទេសស្តង់ដារបស់អគ្គិសនីកម្ពុជា ។ ចំពោះសម្ភារដែលត្រូវភ្ជាប់ពីប្រព័ន្ធអគ្គិសនីកម្ពុជាដល់នាឡិកាស្ទង់ ត្រូវគោរពតាមបញ្ជីម៉ាក Brand Name ដែលអគ្គិសនីកម្ពុជាបានកំណត់ ។ លទ្ធផលនៃការធ្វើតេស្តទៅលើដំណើរការនៃសម្ភារទាំងនោះត្រូវអាចទទួលយកបានដោយអគ្គិសនីកម្ពុជា ។

ដោយឡែកចំពោះថ្លៃពលកម្មក្នុងការតម្លើងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីទាំងអស់អតិថិជនត្រូវបង់ចូលបេឡាអគ្គិសនីកម្ពុជា ដើម្បីអោយអគ្គិសនីកម្ពុជាតម្លើងជូន ដោយពុំអនុញ្ញាតិអោយអតិថិជនតម្លើងដោយខ្លួនឯងឡើយ ។

ផ្សារភ្ជាប់ទៅនឹងចំណុចទី២ខាងលើ អគ្គិសនីកម្ពុជាបានសង្កេតឃើញថា : ទោះបីអគ្គិសនីកម្ពុជាបានសម្របសម្រួលជូនអតិថិជនក្នុងការផ្គត់ផ្គង់សម្ភារដោយខ្លួនឯងក្តី ក៏នៅមានអតិថិជនមួយចំនួនដែលបានផ្គត់ផ្គង់សម្ភារអគ្គិសនីមានការយឺតយ៉ាវ ឬបានផ្គត់ផ្គង់ដែរតែខ្វះផ្នែកណាមួយដែលធ្វើឲ្យរាំងស្ទះ និងអូសបន្លាយដល់ផែនការសកម្មភាពនៃការបន្តចរន្តជូនអតិថិជន និងជះឥទ្ធិពលអវិជ្ជមានមកលើថ្នាក់ដឹកនាំ និងនិយោជិតទទួលខុសត្រូវលើការងារបន្តចរន្តនេះ ។ ដើម្បីបញ្ចៀសបាតុភាពអសកម្មខាងលើនេះ អគ្គិសនីកម្ពុជាសូមធ្វើការណែនាំដល់ជំនាញពាក់ព័ន្ធដូចខាងក្រោមៈ

១-ត្រូវមានកិច្ចសន្យារវាងអតិថិជនធុនមធ្យម-ធុនធំ និងអគ្គិសនីកម្ពុជាស្តីពីរយៈពេលកំណត់ការផ្គត់ផ្គង់សម្ភារអគ្គិសនីដូចខាងក្រោម :

- <u>ប៉ុស្តិ៍លើបង្គោល</u> ៖ អតិថិជនត្រូវប្រគល់សម្ភារអគ្គិសនីមកអគ្គិសនីកម្ពុជា ក្នុងរយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃបានការអនុញ្ញាតិបើកការដ្ឋាន ដើម្បីឲ្យអគ្គិសនីរៀបចំតម្លើងជូន។
- <u>ប៉ុស្តិ៍ចល័ត</u> ៖ អតិថិជនត្រូវប្រគល់សម្ភារអគ្គិសនីជូនអគ្គិសនីកម្ពុជា អោយរៀបចំតម្លើងជូនក្នុងរយៈពេលមិនត្រូវលើសពី 15 (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានការអនុញ្ញាតិបើកការដ្ឋាន ។
- <u>បន្ទប់ភ្លើង</u> ៖ អតិថិជនត្រូវប្រគល់សម្ភារអគ្គិសនីជូនអគ្គិសនីកម្ពុជា អោយរៀបចំតម្លើងជូនក្នុងរយៈពេលមិនត្រូវលើសពី 20 (ម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃបានការអនុញ្ញាតិបើកការដ្ឋាន ។

២-ក្នុងករណីអតិថិជនធុនមធ្យម និងធុនធំ ពុំបានគោរពលក្ខខ័ណ្ឌនៃរយៈពេលផ្គត់ផ្គង់សម្ភារអគ្គិសនីខាងលើទេ

អគ្គិសនីកម្ពុជានឹងពិន័យទឹកប្រាក់ 0.1% ក្នុងមួយថ្ងៃនៃតម្លៃពលកម្មតម្លើងដែលអតិថិជនបានបង់ដោយគិតចាប់ពីថ្ងៃបើកការដ្ឋានទៅ តែចំនួនទឹកប្រាក់ពិន័យនេះមិនត្រូវលើសពី ១០% នៃតម្លៃពលកម្មដែលបានបង់ឡើយ ។

៣-អតិថិជនអាក់ខានប្រគល់សម្ភារលើសរយៈពេល ៣០ (សាមសិប) ថ្ងៃ (គិតពីថ្ងៃអនុញ្ញាតិបើកការដ្ឋាន) អគ្គិសនីកម្ពុជានឹងលុបឈ្មោះអតិថិជនចេញពីបញ្ជីស្នើសុំបន្តចរន្ត រួចបង្វិលតែប្រាក់កក់ដែលបានបង់រួច (បើបានបង់) ជូនអតិថិជនវិញតែប៉ុណ្ណោះ ។

សូមលោកប្រធានសាខាអគ្គិសនីកម្ពុជា អង្គភាពអគ្គិសនីកម្ពុជាខេត្ត-ក្រុង និងការិយាល័យពាក់ព័ន្ធទាំងអស់ត្រូវមានកាតព្វកិច្ចពន្យល់ផ្សព្វផ្សាយឲ្យបានទូលាយ ជម្រាបជូនអតិថិជនឲ្យបានយល់លើសេចក្តីណែនាំនេះ តាំងពីអតិថិជនដាក់ពាក្យស្នើសុំបន្តចរន្តដំបូង និងត្រូវអនុវត្តតាមសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

ចម្លងជូន:
-លោកអគ្គនាយករងអគ្គិសនីកម្ពុជា
-នាយក និងនាយករងពាក់ព័ន្ធ
-ឯកសារ -កាលប្បវត្តិ
« ជ្រាបជាព័ត៌មាន »
-លោកប្រធានការិយាល័យបច្ចេកទេសចែកចាយ
-លោកប្រធានការិយាល័យម៉ាឃីតធីង
-លោកប្រធានការិយាល័យផែនការផ្គត់ផ្គង់សម្ភារ
-លោកប្រធានអង្គភាពបណ្តាញ
-លោកប្រធានអង្គភាពបរិជាន
-លោកប្រធានការិយាល័យគ្រប់គ្រងអាជីវកម្មសាខាអគ្គិសនី
-លោកប្រធានការិយាល័យគ្រប់គ្រងអាជីវកម្មខេត្ត
-លោកស្រីប្រធានការិយាល័យព័ត៌មាន និងសេវាអតិថិជន
-លោកប្រធានគ្រប់សាខាអគ្គិសនីកម្ពុជានៅភ្នំពេញ
-លោកប្រធានគ្រប់អង្គភាពអគ្គិសនីកម្ពុជាខេត្តក្រុងចំណុះអគ្គិសនីកម្ពុជា
« ដើម្បីចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធិភាព »

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**
ELECTRICITE DU CAMBODGE

លេខ: ០៧៨៤ អគក.ឧកក.អនខ

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០២០

# សេចក្តីណែនាំ
## ស្តីពី
## ការបំពេញបែបបទស្នើសុំបន្តចរន្តអគ្គិសនីធុនមធ្យម និងធុនធំ

អតិថិជនស្នើសុំបន្តចរន្តអគ្គិសនីសម្រាប់ប្រើប្រាស់ជាប្រភេទ លំនៅដ្ឋាន អង្គភាពរដ្ឋ ពាណិជ្ជកម្ម ឧស្សាហ-កម្ម និងបុរី ឬសំណង់ផ្ទះល្វែង ដែលបន្តផ្ទាល់ចេញពីត្រង់ស្វូ ឬដំឡើងត្រង់ស្វូ អាចទទួលយកពាក្យស្នើសុំបន្តចរន្តដោយឥតគិតថ្លៃតាមរយៈ៖

- ការិយាល័យទំនាក់ទំនងព័ត៌មាន និងសរុប នៃនាយកដ្ឋានអាជីវកម្មចែកចាយ នៅរៀងរាល់ថ្ងៃធ្វើការ
  - ពេលព្រឹកចាប់ពីម៉ោង ០៧ : ៣០នាទី ដល់ ១២ : ០០នាទី
  - ពេលរសៀលចាប់ពីម៉ោង ១៤ : ០០នាទី ដល់ ១៧ : ៣០នាទី
- ទីតាំងទាញយកឯកសារ: http://www.edc.com.kh/images/application_form_big.pdf
- QR Code

តំណភ្ជាប់ ៖ www.edc.com.kh/id/438938857
លេខសំងាត់ ៖ មិនមាន
សុពលភាព ៖ មិនកំណត់

### ១- ការបំពេញបែបបទស្នើសុំ

អតិថិជនត្រូវបំពេញពាក្យស្នើសុំបន្តចរន្តអគ្គិសនី និងផ្តិតមេដៃ ឬហត្ថលេខា និងត្រា លើឯកសារឧបសម្ព័ន្ធ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួន តាមប្រភេទប្រើប្រាស់នីមួយៗដូចខាងក្រោម ៖

| ប្រភេទប្រើប្រាស់ | ត្រូវភ្ជាប់មកជាមួយ | | | | |
|---|---|---|---|---|---|
| | ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកស្នើសុំ | ឯកសារសំគាល់ទីតាំងស្នើសុំ | ឯកសារបញ្ជាក់ប្រភេទប្រើប្រាស់ | ឯកសារជានាទូទាត់ | ឯកសារផ្សេងៗ |
| លំនៅដ្ឋាន | ✓ | ✓ | | | ✓ |
| អង្គភាពរដ្ឋ | ✓ | | | ✓ | ✓ |
| ពាណិជ្ជកម្ម | ✓ | ✓ | ✓ | ✓[1] | ✓ |
| ឧស្សាហកម្ម | ✓ | ✓ | ✓ | ✓[1] | ✓ |
| បុរី ឬសំណង់ផ្ទះល្វែង | ✓ | | ✓ | | ✓ |

[1] ករណីអ្នកស្នើសុំមិនមែនជាម្ចាស់ទីតាំង

## ២- ឯកសារចាំបាច់ត្រូវភ្ជាប់មកជាមួយ

### ក- ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកស្នើសុំ

- ច្បាប់ចម្លង អត្តសញ្ញាណប័ណ្ណ
- ឬច្បាប់ចម្លង លិខិតឆ្លងដែន
- ឬច្បាប់ដើម លិខិតបញ្ជាក់អត្តសញ្ញាណ របស់អាជ្ញាធរឃុំ/សង្កាត់
- និងដូចចំណុចណាមួយនៃ បីចំណុចខាងលើ (ករណីអ្នកស្នើសុំមិនមែនជាម្ចាស់ទីតាំង)

### ខ- ឯកសារសំគាល់ទីតាំងស្នើសុំ

- ច្បាប់ចម្លង វិញ្ញាបនបត្រសំគាល់អចលនវត្ថុ
- ឬច្បាប់ចម្លង លិខិតផ្ទេរសិទ្ធិកាន់កាប់
- ឬច្បាប់ដើម លិខិតបញ្ជាក់កម្មសិទ្ធិទីតាំង របស់អាជ្ញាធរឃុំ/សង្កាត់
- ច្បាប់ចម្លង សៀវភៅគ្រួសារ (ករណីអ្នកស្នើសុំគ្មានឈ្មោះនៅលើវិញ្ញាបនបត្រសំគាល់អចលនវត្ថុ ឬលិខិតផ្ទេរសិទ្ធិកាន់កាប់)
- ច្បាប់ចម្លង កិច្ចសន្យាជួល (ករណីជួលទីតាំង)

### គ- ឯកសារបញ្ជាក់ប្រភេទប្រើប្រាស់

- ច្បាប់ចម្លង ប័ណ្ណពន្ធប៉ាតង់
- ឬច្បាប់ចម្លង វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

### ឃ- ឯកសារធានាការទូទាត់

- ច្បាប់ដើម លិខិតធានាការទូទាត់ថ្លៃថាមពលអគ្គិសនីពីម្ចាស់កម្មសិទ្ធិ មានបញ្ជាក់ពីអាជ្ញាធរឃុំ/សង្កាត់ ឬមេធាវីដែលទទួលស្គាល់ដោយគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា (ករណីជួលទីតាំង)
- ច្បាប់ដើម លិខិតបញ្ជាក់ការទូទាត់របស់ប្រធានស្ថាប័ន ឬប្រធានអង្គភាពស្នើសុំ (ករណីអង្គភាពរដ្ឋ)
- ច្បាប់ដើម លិខិតធានាទូទាត់ចេញដោយក្រសួងមានសិទ្ធិសម្រេច (ករណីចំណាយថវិការដ្ឋ)

### ង- ឯកសារផ្សេងៗ

- ច្បាប់ដើម លិខិតផ្តល់សិទ្ធិទំនាក់ទំនងការងារ (ករណីម្ចាស់មិនបានទំនាក់ទំនងការងារដោយផ្ទាល់)
- ច្បាប់ដើម លិខិតផ្តល់សិទ្ធិបំពេញបែបបទ មានបញ្ជាក់ពីអាជ្ញាធរឃុំ/សង្កាត់ ឬមេធាវីដែលទទួលស្គាល់ដោយគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា (ករណីម្ចាស់ទីតាំងប្រើប្រាស់តំណាង)
- ច្បាប់ចម្លង ច្បាប់សាងសង់ (ករណីកំពុងសាងសង់)
- ច្បាប់ចម្លង លក្ខន្តិកក្រុមហ៊ុន (ករណីជាក្រុមហ៊ុន)
- ប្លង់មេរបស់បុរីមានបញ្ជាក់ពីចំនួនផ្ទះ និងប្រភេទសំណង់ព្រមទាំងប្លង់បញ្ជាក់ទីតាំងដំឡើងគ្រង់ស្សូរ និងខ្សែបណ្តាញតង់ស្យុងទាប មានប្រថាប់ត្រារបស់បុរី (ករណីទីតាំងជាបុរី)
- វិក្កយបត្រថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ឬឯកសារបន្តចរន្តអគ្គិសនីចាស់ (ករណីស្នើសុំបង្កើនកម្លាំង)
- អតិថិជនត្រូវស្នើសុំប្តូរឈ្មោះជាមុន មុនពេលស្នើសុំបង្កើនកម្លាំងប្រើប្រាស់អគ្គិសនី (ករណីប្រព័ន្ធនាឡិកាស្ទង់ចាស់ មិនមែនជាឈ្មោះរបស់ម្ចាស់កម្មសិទ្ធិថ្មី)

**បញ្ជាក់:**

- គ្រប់ឯកសារថតចម្លងទាំងអស់ត្រូវមានប្រថាប់ត្រាពីអាជ្ញាធរមូលដ្ឋាន(ករណីទូទៅ) ឬប្រថាប់ត្រារបស់បុរី (ករណីជាបុរី)។
- ករណីអតិថិជនឧស្សាហកម្មគ្មានប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ភ្ជាប់មកជាមួយ នោះអគ្គិសនីកម្ពុជានឹងចាត់បញ្ចូលជាប្រភេទអតិថិជនពាណិជ្ជកម្ម។
- រាល់ការបំពេញបែបបទស្នើសុំបន្តចរន្តអគ្គិសនី ហាមកោសលុប។
- ចំពោះអតិថិជននៅរាជធានីភ្នំពេញ សូមដាក់ពាក្យស្នើសុំបន្តចរន្តអគ្គិសនី នៅការិយាល័យទំនាក់ទំនងព័ត៌មាន និងសរុប នៃនាយកដ្ឋានអាជីវកម្មចែកចាយ ដោយឡែកអតិថិជននៅតាមបណ្តាខេត្តនានា សូមដាក់ពាក្យស្នើសុំបន្តចរន្តអគ្គិសនី នៅតាមបណ្តាអង្គភាពអគ្គិសនីខេត្តពាក់ព័ន្ធដែលជាសាខារបស់អគ្គិសនីកម្ពុជា។

គ្រប់ការិយាល័យ និងអង្គភាពអគ្គិសនីពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

**ចម្លងជូន:**

- អគ្គនាយករង អគ្គិសនីកម្ពុជា
- គ្រប់នាយកដ្ឋាន អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតផ្តល់សិទ្ធិទំនាក់ទំនងការងារ

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ .......................................... ជាអក្សរឡាតាំង ............................................. ជនជាតិ .................. សញ្ជាតិ................. មុខរបរ......................................... អាសយដ្ឋាន ផ្ទះលេខ ............... ផ្លូវ ........... ភូមិ............................... ឃុំ-សង្កាត់ ................................... ស្រុក-ខណ្ឌ .............................. ខេត្ត-រាជធានី ............. លេខទូរស័ព្ទ...........................WhatsApp:.........................Telegram:................... E-mail.......................................។

**សូមគោរពជូន**
**លោកនាយកអាជីវកម្មចែកចាយ នៃអគ្គិសនីកម្ពុជា**

**កម្មវត្ថុ** : សំណើសុំផ្តល់សិទ្ធិទំនាក់ទំនងទទួលព័ត៌មាន និងរៀបចំឯកសារស្នើសុំបន្តចរន្តអគ្គិសនី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ ខាងលើខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបជូន លោកនាយក មេត្តាជ្រាបថា៖ ដោយខ្ញុំបាទ-នាងខ្ញុំពុំអាចមកទំនាក់ទំនងព័ត៌មាន និងរៀបចំឯកសារស្នើសុំបន្តចរន្តអគ្គិសនីដោយផ្ទាល់បាន ដូច្នេះ ខ្ញុំបាទ-នាងខ្ញុំ ស្នើសុំការអនុញ្ញាតប្រគល់ភារកិច្ចនេះជូន លោក-លោកស្រីឈ្មោះ............................................... អត្តសញ្ញាណប័ណ្ណលេខ:..........................លេខទូរស័ព្ទ:..................... WhatsApp: .............................. Telegram: ....................................។

**សូមជូនភ្ជាប់មកជាមួយនូវ** ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណអ្នកទទួលសិទ្ធិ ដែលមានស្នាមមេដៃ និង បញ្ជាក់ពី អាជ្ញាធរមូលដ្ឋាន ចំនួន ០១ច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោកនាយក មេត្តាទទួលស្គាល់ ដោយក្តីអនុគ្រោះ។
សូម លោកនាយក មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ...........................ខែ..............ឆ្នាំ..................ព.ស ២៥....
................., ថ្ងៃទី..........ខែ...........ឆ្នាំ២០......

**ស្នាមមេដៃ អ្នកទទួលសិទ្ធ**

**ស្នាមមេដៃ ឬហត្ថលេខា និងត្រា**
**ម្ចាស់ទីតាំងស្នើសុំបន្តចរន្ត**